# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

**គ.ជ.ប NEC BULLETIN**

លេខ ១ ចេញផ្សាយថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

Issue 1 : 10 / 4 / 2023


# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## ការចាប់ផ្តើមដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពី



**តទៅទំព័រទី២**

**មាតិកា៖** **ទំព័រ**


- ការចាប់ផ្តើមដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ..................១
- លទ្ធផលនៃជំនួបសវនាការរវាងប្រធាន គ.ជ.ប ជាមួយឯកអគ្គរាជទូតជប៉ុន ..................៤
- ប្រធាន គ.ជ.ប ទទួលជួបក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នា ..................៧
- លទ្ធផលនៃដំណើរទស្សនកិច្ចសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ អំពីការរៀបចំការបោះឆ្នោត ..................៨
- គ.ជ.ប ចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោត ..................១០
- គ.ជ.ប ចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោត ..................១០
- ឯកឧត្តមប្រធាន គ.ជ.ប ជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃ គ.ជ.ប ..................១១
- គ.ជ.ប កម្ពុជា និង គ.ជ.ប ប៉ាឡេស្ទីន បានជួបផ្លាស់ប្តូរទស្សនៈ និងបទពិសោធន៍ ពាក់ព័ន្ធនឹងការងារ ..................១៣
- គ.ជ.ប បើកវគ្គបណ្តុះបណ្តាលស្តីពី របៀបប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះ ..................១៤
- ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ..................១៦

តមកពីទំព័រទី១ **ការចាប់ផ្តើមដំណើរការ ...**

ការចាប់ផ្តើមដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងការចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

ក្នុងកិច្ចប្រជុំនោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា អំពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោត ដែលផ្តើមចេញពីមូលដ្ឋាននោះ គ.ជ.ប បានត្រៀមខ្លួន និងបានរៀបចំជាស្រេចនូវផែនការមេ ប្រតិទិនការងារ និងបានធ្វើបច្ចុប្បន្នភាពលើបទបញ្ញា និងនីតិវិធី រួមទាំងឯកសារគតិយុត្តផ្សេងទៀត ដើម្បីធានាឱ្យការរៀបចំចាត់ចែងការងារបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ ប្រព្រឹត្តទៅដោយរលូន និងជោគជ័យ។



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ឯកឧត្តម បានមានប្រសាសន៍បន្ថែមទៀតថា ចាប់ពីពេលនេះរហូតដល់ថ្ងៃបោះឆ្នោត គ.ជ.ប មានការងារជាច្រើនដែលត្រូវធ្វើជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយការងារទាំងនោះត្រូវអនុវត្តតាមដំណាក់កាល និងមានកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់។

ឯកឧត្តមប្រធាន គ.ជ.ប បានមានប្រសាសន៍អំពី ការរៀបចំបញ្ជីបោះឆ្នោត អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ សរុបមានចំនួន ៩.៧១០.៦៥៩នាក់ស្មើនឹង ៨៩,២៨% នៃស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត ក្នុងនោះស្ត្រីមានចំនួន ៥.១៦១.៩០៩នាក់ និងមានការិយាល័យបោះឆ្នោត សរុបចំនួន ២៣.៧៨៩ការិយា-ល័យ។



សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ពាក់ព័ន្ធនឹងប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧ ឯកឧត្តមប្រធាន បានមានប្រសាសន៍អំពីបែបបទ កាលបរិច្ឆេទនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត និងការប្រកាសផ្សាយលទ្ធផលនៃការបោះឆ្នោត។

ចំពោះលទ្ធផលផ្លូវការនៃការបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបញ្ជាក់ជូនថា ក្រោយពីការដោះស្រាយពាក្យ-បណ្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតចប់រួចរាល់ជាស្ថាពរ គ.ជ.ប នឹងប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោត លទ្ធផលនៃការបែងចែកអាសនៈ និងប្រកាសផ្សាយបេក្ខជនជាប់ឆ្នោត ជូនសាធារណជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

មានសំណួរ និងសំណូមពរមួយចំនួនបានលើកឡើង



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ



**តំណាងភាគីពាក់ព័ន្ធមានសំណួរ និងសំណូមពរក្នុងកិច្ចប្រជុំ**

ដោយភាគីចូលរួមក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងអ្នកសង្កេតការណ៍ថ្នាក់ជាតិ ការឈរឈ្មោះជាបេក្ខជន ការលើកស្លាកគណបក្សនយោបាយ នៅមូលដ្ឋាន និងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ គ.ជ.ប រួមជាមួយស្ថាប័នរដ្ឋាភិបាលទៅសាធារណរដ្ឋបារាំងក្នុងពេលថ្មីៗនេះ និងសំណូមពរឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតដើម្បីជួយប្រទេសកម្ពុជាមានប្រជាធិបតេយ្យកាន់តែរឹងមាំ ព្រមទាំងសំណូមពរឱ្យមានការប្រកួតប្រជែងប្រកបដោយគុណធម៌ ទទួលយកការពិតបែបវិទ្យាសាស្ត្រ និងត្រូវចេះទទួលយកលទ្ធផលនៃការបោះឆ្នោត ជាជាងបង្កបញ្ហាដើម្បីឱ្យបរទេសយកប្រជាធិបតេយ្យមកឱ្យកម្ពុជា។

គ.ជ.ប បានឆ្លើយទៅនឹងសំណួរ និងពន្យល់ដល់ភាគីពាក់ព័ន្ធទាំងអស់មួយចំណុចម្តងៗ ដើម្បីបានយល់ និងបានបញ្ជាក់ជូនថា ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនេះ គ.ជ.ប នឹងមានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធតាមដំណាក់កាល និងតាមប្រធានបទនីមួយៗជាបន្តទៀត។ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ គឺជាថ្ងៃដំបូងនៃការប្រកាសផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។



**តំណាងភាគីពាក់ព័ន្ធមានសំណួរ និងសំណូមពរក្នុងកិច្ចប្រជុំ**

ចំពោះលទ្ធផលនៃដំណើរទស្សនកិច្ចនៅសាធារណរដ្ឋបារាំង គ.ជ.ប បានមើលឃើញថា ប្រព័ន្ធបោះឆ្នោតនៅប្រទេសបារាំងខុសពីប្រទេសកម្ពុជា ហើយមានប្រទេសតិចណាស់ដែលរៀបចំការបោះឆ្នោតដូចប្រទេសបារាំង។ ប្រទេសបារាំងបានកសាងច្បាប់ និងរៀបចំការបោះឆ្នោតតាំងពីយូរមកហើយ មុនការបោះឆ្នោតនៅប្រទេសកម្ពុជាទៅទៀត។ ជារួមមានចំណុចខ្លះ ប្រទេសកម្ពុជាយើងមានលក្ខណៈប្រសើរជាង និងងាយស្រួលជាង។



**តំណាងភាគីពាក់ព័ន្ធមានសំណួរ និងសំណូមពរក្នុងកិច្ចប្រជុំ**

មុននឹងបញ្ចប់កិច្ចប្រជុំ ឯកឧត្តមប្រធាន គ.ជ.ប បានគូសបញ្ជាក់ថា គ.ជ.ប ជាអាជ្ញាកណ្តាលដែលអនុវត្តតាមច្បាប់បោះឆ្នោត និងអនុវត្តតាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលបានចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធ។ ឯកឧត្តមសង្ឃឹមជឿជាក់ប្រកបដោយសុទិដ្ឋិនិយមថា ភាគីពាក់ព័ន្ធទាំងអស់នឹងពង្រឹងការចូលរួមសហការជាមួយ គ.ជ.ប ស្របតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ក្រមសីលធម៌ និងសេចក្តីណែនាំផ្សេងៗ ដើម្បីធ្វើយ៉ាងណាធានាឱ្យដំណើរការនេះប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ។ មួយវិញទៀត ក្នុងកាលៈទេសៈដែលជំងឺកូវីដ-១៩ មិនទាន់ផុតរលត់ ឯកឧត្តម ក៏សូមអំពាវនាវយ៉ាងទទូចឱ្យភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋទាំងអស់បន្តការប្រុងប្រយ័ត្ន និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាលតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវទៅចាក់វ៉ាក់សាំងដូសជំរុញតាមការកំណត់ឱ្យបានគ្រប់ៗគ្នា។

នេះជាកិច្ចប្រជុំលើកទី១ ជាមួយភាគីពាក់ព័ន្ធ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមានសមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ មានតំណាងមកពីក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងគណបក្សនយោបាយ មន្ត្រីមកពីស្ថានទូតជប៉ុន តំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកសារព័ត៌មានផងដែរ ចំនួនប្រមាណ ៧០នាក់។

---

# លទ្ធផលនៃជំនួបសវនាការរវាងប្រធាន គ.ជ.ប ជាមួយឯកអគ្គរាជទូតជប៉ុន



(រូបខាងស្តាំ) ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និង ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា

ឆ្លើយតបតាមសំណើរបស់ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួបសវនាការជាមួយ ឯកឧត្តម **អ៊ូអិណុ អាត់ស៊ូស៊ី** (H.E. Mr. UENO Atsushi) ឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្តែងការគួរសម និងផ្លាស់ប្តូរយោបល់នានាជុំវិញស្ថានភាពទូទៅនៃដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានមតិស្វាគមន៍ ឯកឧត្តម **អ៊ូអិណុ អាត់ស៊ូស៊ី** ដែលបានអញ្ជើញមកដល់ទីស្តីការ គ.ជ.ប និងបានថ្លែងអំណរគុណដល់ប្រទេសជប៉ុន ដែលបានជួយដល់ គ.ជ.ប តាំងពីឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន ដែលសរុបជាទឹកប្រាក់មានជាង ១០លានដុល្លារ មានជំនួយជាសម្ភារ ស៊ើរវើ (server) សម្រាប់ផ្ទុកទិន្នន័យអ្នកបោះឆ្នោត រថយន្ត ហិបឆ្នោត និងជំនាញការបច្ចេកទេសមកពីប្រទេសជប៉ុន។ បច្ចុប្បន្នតាមរយៈអង្គការ JICA គ.ជ.ប ក៏មានជំនាញការមួយរូបកំពុងជួយដល់ការងារអប់រំអ្នកបោះឆ្នោត។



សកម្មភាពក្នុងជំនួបពិភាក្សា

ភាគីជប៉ុនក៏បានថ្លែងអំណរគុណដល់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ដែលបានចំណាយពេលវេលាទទួលជួបពិភាក្សាការងារពាក់ព័ន្ធនឹងការបោះឆ្នោត និងបានរំលឹកឡើងអំពីទំនាក់ទំនងល្អរវាងប្រទេសជប៉ុន ជាមួយប្រទេសកម្ពុជា ក្នុងការស្វែងរកសន្តិភាពនៅកម្ពុជា។ លើសពីនេះ ស្ថានទូតជប៉ុនក៏មានទំនាក់ទំនងល្អជាមួយ គ.ជ.ប ផងដែរ ដោយមានកិច្ចសហប្រតិបត្តិការជាមួយគ្នាជាបន្តបន្ទាប់។ ក្នុងការជួបពិភាក្សានេះ ភាគីជប៉ុនក៏ចង់ស្វែងយល់ពី គ.ជ.ប អំពីការរៀបចំការបោះឆ្នោតក្នុងឆ្នាំ២០២៣ នេះ និងដំណើរទស្សនកិច្ចរបស់ គ.ជ.ប ទៅកាន់សាធារណរដ្ឋបារាំង នាពេលថ្មីៗកន្លងមកនេះ។

ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនដល់ភាគីជប៉ុន ដូចតទៅ៖

ចាប់តាំងពីឆ្នាំ១៩៩៨ មក គ.ជ.ប កម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯង ចំនួន ១៦ លើក រួចមកហើយ ដែលការបោះឆ្នោតនោះបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ សម្រាប់ពេលខាងមុខ គ.ជ.ប កំពុងរៀបចំការបោះឆ្នោតចំនួន ២ គឺការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ចំនួន ៥ ដែលទើបបំបែក និងបង្កើតថ្មី នៅក្នុងខេត្តចំនួន ៣ មានខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ និងការបោះឆ្នោតមួយទៀត ជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។



**សកម្មភាពក្នុងជំនួបពិភាក្សា**

ផ្អែកលើច្បាប់ជាមូលដ្ឋាន គ.ជ.ប ត្រូវរៀបចំធ្វើយ៉ាងណាឱ្យការបោះឆ្នោតនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានការទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។ គ.ជ.ប មានរចនាសម្ព័ន្ធបោះឆ្នោតនៅថ្នាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅថ្នាក់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត នៅថ្នាក់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងថ្នាក់គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ គ.ជ.ប ត្រូវរៀបចំ និងអនុម័តបទបញ្ជា និងនីតិវិធី នៃការបោះឆ្នោត ប្រតិទិននៃការបោះឆ្នោត ផែនការមេ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដើម្បីអនុវត្តតាមការងារជាក់ស្តែង។

ឯកឧត្តម ក៏បានជម្រាបជូនថា ការបោះឆ្នោតនៅកម្ពុជាមាន ៤ ដំណាក់កាល គឺដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ



**ឯកឧត្តមប្រធាន គ.ជ.ប ប្រគល់វត្ថុអនុស្សាវរីយ៍ ជូន ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**

និងការចុះឈ្មោះបោះឆ្នោត ដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដំណាក់កាលនៃការឃោសនាបោះឆ្នោត និងដំណាក់កាលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

ចំពោះដំណាក់កាលទី១ គ.ជ.ប បានអនុវត្តចប់សព្វគ្រប់ហើយដែលអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានជាង ៩លាននាក់ ស្មើនឹង ៨៩,២៨% ធៀបនឹងចំនួនប្រជាពលរដ្ឋដែលមានអាយុ ១៨ ឆ្នាំឡើង។ គ.ជ.ប ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាបន្ថែមទូទាំងប្រទេស សរុបប្រមាណ ១៥ ម៉ឺននាក់ ដែលមន្ត្រីទាំងនោះមាននៅថ្នាក់ គ.ជ.ប ថ្នាក់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។ ហើយនៅពេលខាងមុខ គ.ជ.ប នឹងបន្តជ្រើសរើសគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ជាបន្តទៀត។ មន្ត្រីជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសទាំងនោះនឹងត្រូវធ្វើការបណ្តុះបណ្តាលជាបន្តបន្ទាប់។

នៅថ្ងៃទី២៤ ខែមេសា ខាងមុខនេះ គឺជាដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។ គណបក្សនយោបាយដែលចុះបញ្ជីស្របច្បាប់នៅក្រសួងមហាផ្ទៃ អាចដាក់បញ្ជីគណបក្ស និងបេក្ខជនឈរឈ្មោះបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ គណបក្សនយោបាយមួយចំនួនបាននិងកំពុងរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនជាបណ្តើរៗហើយ ដោយ គ.ជ.ប បានជួយសម្រួលផ្តល់ដល់គណបក្សនយោបាយនូវកម្មវិធីគ្រប់គ្រងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ត្រៀមការងារជាមុន ហើយ

អាចនឹងមានគណបក្សនយោបាយជាច្រើនចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខនេះ។

គណបក្សនយោបាយមានសិទ្ធិធ្វើការឃោសនាតាមគ្រប់រូបភាព និងតាមធនធានរបស់ខ្លួន នៅតាមទីសាធារណៈ។ លើសពីនេះ គ.ជ.ប រៀបចំកម្មវិធីស្មើភាពសម្រាប់គណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់គណបក្ស ផ្សាយតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ។

សម្រាប់ការបោះឆ្នោតនៅពេលខាងមុខនេះ ការិយាល័យបោះឆ្នោត សរុបទាំងអស់មាន ចំនួន ២៣.៧៨៩ ការិយាល័យ ដែលការបោះឆ្នោតចាប់ផ្ដើមបើកដំណើរការពីម៉ោង៧:០០ព្រឹក ដល់ម៉ោង ១៥:០០រសៀល។ ដំណើរការរាប់សន្លឹកឆ្នោតត្រូវអនុវត្តនៅនឹងការិយាល័យបោះឆ្នោតនោះតែម្ដង បន្ទាប់ពីបិទការបោះឆ្នោត។ ភ្នាក់ងារនៃគណបក្សនយោបាយ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានសិទ្ធិប្ដឹងតវ៉ាក្នុងករណីសង្កេតឃើញមានភាពមិនប្រក្រតី។

ចំពោះការសង្កេតការណ៍បោះឆ្នោត ឯកឧត្តមប្រធានបានបញ្ជាក់ថា គ.ជ.ប តែងតែអញ្ជើញអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីឱ្យចូលរួមសង្កេតមើលគ្រប់ការបោះឆ្នោត ហើយនៅពេលខាងមុខនេះ គ.ជ.ប ក៏នឹងអញ្ជើញអ្នកសង្កេតការណ៍ឱ្យចូលរួមសង្កេតមើលការបោះឆ្នោតនេះផងដែរ។ ជាពិសេសទៅទៀត គ.ជ.ប នឹងអញ្ជើញស្ថានទូត នៃប្រទេសនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យមើលការបោះឆ្នោត។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបញ្ជាក់បន្ថែមថា កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទ ១១០២) ត្រូវបានបិទផ្សាយនៅមុខការិយាល័យបោះឆ្នោត ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយថតទុកជាឯកសារ ហើយនៅយប់ថ្ងៃបោះឆ្នោត គ.ជ.ប ធ្វើការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ។

ឯកឧត្តមប្រធាន គ.ជ.ប បានបញ្ជាក់ទៀតថា ចំពោះការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោត ត្រូវធ្វើឡើងតាមឋានានុក្រមតាំងពីថ្នាក់គណៈកម្មការការិយាល័យបោះឆ្នោត ថ្នាក់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ថ្នាក់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ថ្នាក់ គ.ជ.ប និងដល់ក្រុមប្រឹក្សាធម្មនុញ្ញ។

ពាក់ព័ន្ធនឹងការអប់រំអ្នកបោះឆ្នោត ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនថា ដោយមានកិច្ចសហប្រតិបត្តិការជាមួយជំនាញការបោះឆ្នោតមកពីអង្គការ JICA ប្រចាំនៅ គ.ជ.ប គ.ជ.ប បានចុះទៅធ្វើការផ្សព្វផ្សាយអប់រំជាប្រចាំដល់សិស្ស និស្សិត នៅតាមសាលារៀន និងសាកលវិទ្យាល័យមួយចំនួន។ ក្រៅពីនេះ គ.ជ.ប បានផលិតឯកសារ និងកម្មវិធីអប់រំផ្សព្វផ្សាយ ដើម្បីធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីការបោះឆ្នោតបន្ថែមទៀត។

ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចសង្កេតមើលការបោះឆ្នោតនៅសាធារណរដ្ឋបារាំង ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា ប្រព័ន្ធបោះឆ្នោតនៅប្រទេសបារាំង មិនដូចប្រព័ន្ធបោះឆ្នោតនៅកម្ពុជាទេ ក៏ប៉ុន្តែការរៀបចំការបោះឆ្នោតមានគោលដៅដូចគ្នា គឺការបោះឆ្នោតត្រូវតែប្រកាន់យកតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

បន្ទាប់ពីបានស្ដាប់ការពន្យល់បកស្រាយរបស់ ឯកឧត្តមប្រធាន គ.ជ.ប រួចមក ភាគីជប៉ុនបានវាយតម្លៃខ្ពស់ចំពោះ គ.ជ.ប កម្ពុជា ដែលបានរៀបចំការបោះឆ្នោតដោយខ្លួនឯងយ៉ាងទៀងទាត់ ហើយសម្រេចបានលទ្ធផលល្អ។ សម្រាប់ការបោះឆ្នោតឆ្នាំ២០២៣ នេះ ភាគីជប៉ុនសង្ឃឹមថា នឹងប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ផងដែរ។ ឯកឧត្តម **អ៊ូអិណូ អាត់ស៊ូស៊ី** បានបន្តទៀតថា ឯកឧត្តម នឹងឆ្លៀតឱកាសជួបពិភាក្សាគ្នាជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ជាពិសេសទៅទៀតកំពុងពិចារណាជួយដល់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងស្រុក ផងដែរ។

ជាចុងក្រោយ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានសំណូមពរដល់ភាគីជប៉ុន ជួយជំរុញឱ្យភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ស្វែងយល់ពីច្បាប់ បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតឱ្យបានត្រឹមត្រូវ ពីព្រោះថា គណបក្សនយោបាយខ្លះតែងតែប្ដឹងដោយពុំមានភស្តុតាងត្រឹមត្រូវ រួចធ្វើការរិះគន់មកលើស្ថាប័ន គ.ជ.ប ពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹង។ ឯកឧត្តមប្រធាន បានជូនពរឱ្យការបំពេញបេសកកម្មរបស់ ឯកឧត្តម **អ៊ូអិណូ អាត់ស៊ូស៊ី** សម្រេចបានជោគជ័យ។

ភាគីជប៉ុនបានថ្លែងអំណរគុណដល់ឯកឧត្តម **ប្រាជ្ញ ចន្ទ** ហើយបានបញ្ជាក់ថា ប្រសិនបើមានឱកាស ភាគីជប៉ុននឹងអញ្ជើញប្រធាន គ.ជ.ប ទៅមើលការបោះឆ្នោតនៅប្រទេសជប៉ុន៕

# ប្រធាន គ.ជ.ប ទទួលជួបក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នា

ឆ្លើយតបតាមសំណើរបស់អង្គការសីលការ នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួបសមាសភាពក្រុមការងារ



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

ស្ត្រីនៃអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៦ រូប ដែលបានស្នើសុំពិភាក្សាអំពី ការបង្កើនបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងសមភាពយេនឌ័រក្នុងវិស័យនយោបាយ។

ក្នុងជំនួបពិភាក្សាការងារនោះ តំណាងក្រុមស្ត្រីដើម្បីទាំងអស់គ្នា បានលើកឡើងថា ក្រុមស្ត្រីដើម្បីទាំងអស់គ្នា ចង់បានវិធានការពិសេសក្នុងការជំរុញស្ត្រីដើម្បីបានដើរតួនាទីស្មើបុរស ដោយផ្អែកលើសិក្ខាសាលារៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល នៅសណ្ឋាគារកាំបូឌីយ៉ាណា កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ហើយមានការចូលរួមពីតំណាងគណបក្សនយោបាយ ចំនួន ១៦។ ម្យ៉ាងទៀត ស្នើសុំគាំទ្រឱ្យមានការធ្វើវិសោធនកម្មច្បាប់ ដោយ



**សកម្មភាពក្នុងជំនួបពិភាក្សា**

កំណត់កូតាស្ត្រីជាបេក្ខជនចំនួនជាភាគរយ ឬក៏ដាក់ឈ្មោះបេក្ខជនឆ្លាស់គ្នា ស្រី ១ ប្រុស ១។ តំណាងក្រុមស្ត្រីដើម្បីទាំងអស់គ្នា បានបន្តថា បទពិសោធន៍នៅប្រទេសចំនួន ៥ ទទួលបានជោគជ័យក្នុងការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ។

បន្ទាប់ពីបានស្ដាប់ការពន្យល់លើកឡើងរបស់ក្រុមស្ត្រីដើម្បីទាំងអស់គ្នារួចមក ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានថ្លែងអំណរគុណដល់សមភាគីស្ត្រីទាំងអស់ ដែលបានចែករំលែកព័ត៌មាន និងមានឆន្ទៈលើកកម្ពស់តួនាទីស្ត្រី និងសមភាពយេនឌ័រក្នុងវិស័យនយោបាយ។ ឯកឧត្តមប្រធាន គ.ជ.ប បានបន្តថា គ.ជ.ប គាំទ្រការលើកកម្ពស់តួនាទីស្ត្រីក្នុងវិស័យនយោបាយ ក្នុងដែនសមត្ថកិច្ច គ.ជ.ប។ ចំនួនស្ត្រីជាបេក្ខជន ផ្អែកលើការដាក់បេក្ខភាពរបស់



**សកម្មភាពក្នុងជំនួបពិភាក្សា**

គណបក្សនយោបាយនីមួយៗ ហើយអ្វីគួរឱ្យកត់សម្គាល់នោះ គណបក្សនីមួយៗបានគិតពីគុណភាពបញ្ជីបេក្ខជនរបស់ខ្លួន។ ចំពោះការសុំធ្វើវិសោធនកម្មច្បាប់ មិនស្ថិតក្នុងដែនសមត្ថកិច្ច គ.ជ.ប ទេ។

ឯកឧត្តមប្រធាន បានបន្ថែមទៀតថា គ.ជ.ប តែងតែលើកទឹកចិត្ត និងកំពុងបង្កើនស្ត្រីក្នុងវិស័យការងាររដ្ឋបាល និងជាមន្ត្រីបោះឆ្នោត។ គ.ជ.ប មានមោទនភាពចំពោះការកើនឡើងនូវសមត្ថភាព និងចំនួនស្ត្រីក្នុងសង្គម។ ដូចនេះ ក្រុមស្ត្រីដើម្បីទាំងអស់គ្នា មិនត្រូវអស់សង្ឃឹមទេ ប៉ុន្តែត្រូវការពេលវេលា។

ជាចុងក្រោយភាគីក្រុមស្ត្រីដើម្បីទាំងអស់គ្នា ដែលមានទីប្រឹក្សាឯករាជ្យ និងជាសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា តំណាងអង្គការសីលការ តំណាងអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បី

កម្ពុជា និងតំណាងអង្គការខុមហ្វ្រែល បានថ្លែងអំណរគុណដល់ឯកឧត្តម **ប្រាជ្ញ ចន្ទ** ដែលបានចំណាយពេលវេលាដើម្បីជួបពិភាក្សាការងារ។

ជំនួបពិភាក្សាការងារបានប្រព្រឹត្តទៅអស់រយៈពេលប្រមាណមួយម៉ោងប្រកបដោយភាពស្និទ្ធស្នាលនិងយោគយល់គ្នា៕

# លទ្ធផលនៃដំណើរទស្សនកិច្ចសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ អំពីការរៀបចំការបោះឆ្នោតនៅសាធារណរដ្ឋបារាំង

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ ដើម្បីសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោត នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ បានធ្វើមាតុភូមិនិវត្តន៍មកដល់មាតុប្រទេសវិញ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៣ ប្រកបដោយសុខសុវត្ថិភាព និងទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា។

ថ្លែងនៅក្នុងឱកាសសន្និសីទសារព័ត៌មាន ពេលត្រឡប់មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (ច្រក VIP) ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប មានប្រសាសន៍ថា ដោយទទួលបានការអនុញ្ញាតពី ឯកឧត្តមប្រធាន គ.ជ.ប និងជាប្រធានគណៈប្រតិភូកម្ពុជា នៅក្នុងដំណើរបំពេញបេសកកម្មនៅសាធារណរដ្ឋបារាំងនេះ ប្រតិភូកម្ពុជាទទួលបានការសម្របសម្រួលយ៉ាងល្អពីក្រសួងមហាផ្ទៃ នៃប្រទេសបារាំង ក៏ដូចជាឯកឧត្តមឯកអគ្គរដ្ឋទូត និងមន្ត្រីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសបារាំង។ ក្នុងដំណើរទស្សនកិច្ចនេះភាគច្រើនប្រតិភូកម្ពុជាបានជួបជាមួយស្ថាប័នរៀបចំការបោះឆ្នោតបារាំង និងស្ថាប័នមួយចំនួនទៀតពាក់ព័ន្ធនឹងការបោះឆ្នោតនៃប្រទេសបារាំង។ ប្រព័ន្ធបោះឆ្នោតបារាំងមិនដូចកម្ពុជាទេ ដោយបារាំងបានរៀបចំការបោះឆ្នោតតាំងពីសតវត្សរ៍ទី១៩ មក និងបានកែលម្អប្រព័ន្ធបោះឆ្នោតរបស់ខ្លួនជាបន្តបន្ទាប់ ហើយរហូតដល់បច្ចុប្បន្ន បារាំងកំពុងប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើប។

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប បានបញ្ជាក់អំពីស្ថាប័នដែលប្រតិភូកម្ពុជាបានជួប រួមមាន ទី១ ក្រសួងមហាផ្ទៃបារាំងដែលជាស្ថាប័នរៀបចំការបោះឆ្នោតផ្ទាល់ មិនដូចជានៅកម្ពុជាមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយឡែក ដែលឯករាជ្យក្នុងការរៀបចំការបោះឆ្នោតនោះទេ។ ក្រសួងមហាផ្ទៃបារាំង មានបណ្តាញរៀបចំការបោះឆ្នោត ដែលជាអាជ្ញាធរក្រុង ខេត្ត និងឃុំ សង្កាត់។ ទី២ ក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សាធម្មនុញ្ញ ដោយស្ថាប័នទាំងពីរនេះ មានកាតព្វកិច្ចដោះស្រាយបណ្តឹងបោះឆ្នោត និងស្ថាប័នមួយចំនួនទៀត ដូចជាស្ថាប័ននិយ័តកម្មសោតទស្សន៍ និងឌីជីថល ដែលជាស្ថាប័នសម្របសម្រួល សម្រាប់ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ។

គណៈប្រតិភូកម្ពុជាត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ និងបានផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានពីគ្នាទៅវិញទៅមក។ ជាមួយគ្នានេះ គណៈប្រតិភូក៏បានលើកឡើងអំពីការងាររៀបចំការបោះឆ្នោតរបស់កម្ពុជាជូនភាគីបារាំងឱ្យបានជ្រាបផងដែរ។ ជារួម ក្នុងដំណើរទស្សនកិច្ចនៅប្រទេសបារាំងរបស់គណៈប្រតិភូកម្ពុជា បានការចូលរួមគ្រប់កម្មវិធីដែលបានគ្រោងទុក និងបានដំណើរការយ៉ាងល្អ។

ចំពោះលទ្ធផល ឯកឧត្តម **ទេព នីថា** បានគូសបញ្ជាក់លើ ៣ ចំណុច សំខាន់ៗរួមមាន៖

ទី១. យើងបានស្វែងយល់អំពីប្រព័ន្ធបោះឆ្នោតនៅប្រទេសបារាំង ហើយកម្ពុជាក៏បានជម្រាបជូនពីដំណើរការនៃប្រព័ន្ធបោះឆ្នោតរបស់ខ្លួនជូនដល់ស្ថាប័នពាក់ព័ន្ធនៃបារាំងដែរ។ យើងបានពង្រឹងទំនាក់ទំនងល្អជាមួយស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតបារាំង។

ទី២. ការបោះឆ្នោតនៅប្រទេសបារាំង បើប្រៀបធៀបនឹងប្រព័ន្ធបោះឆ្នោតកម្ពុជា មិនដូចគ្នាទេ តែមានចំណុចបច្ចេកទេសមួយចំនួនល្អ ដែលយើង



**ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប**

សង្កេតឃើញបារាំងបានរៀបចំនីតិវិធីនៃការបោះ-ឆ្នោតនីមួយៗជាស្រេច ហើយនៅពេលបោះឆ្នោត បានកែសម្រួលបន្តិចបន្តួច ជាសេចក្តីសម្រេចជាមូលដ្ឋានគតិយុត្ត ដាក់ប្រើប្រាស់ ខុសពីកម្ពុជាយើង ដែលយើងធ្វើនីតិវិធីថ្មីសម្រាប់ការបោះឆ្នោតនីមួយៗ។ ទម្រង់បែបបទរៀបចំការបោះឆ្នោតបារាំង សម្រាប់ខេត្ត ឬឃុំ សង្កាត់របស់ខ្លួនមានពណ៌ផ្សេងគ្នា ដែលងាយស្រួលចំណាំ។

ទី៣. បារាំងបានប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើបច្រើន ដែលជាជំនួយក្នុងការគ្រប់គ្រង និងផ្ទៀងផ្ទាត់ក្នុងការបោះឆ្នោត។ ចំណុចគួរឱ្យចាប់អារម្មណ៍មួយទៀត គឺមេឃុំ ជាប្រធានការិយាល័យបោះឆ្នោតតែម្តង។ ក្នុងករណីការិយាល័យមានច្រើន មេឃុំទាំងនោះចាត់តាំងមន្ត្រីរបស់ខ្លួនធ្វើជាប្រធានការិយាល័យបោះឆ្នោតតែម្តង និងមានជំនួយការពីរនាក់ទៀត។ នៅពេលបោះឆ្នោតម្តងៗ បារាំងមិនមានការបង្រៀន ឬរៀបចំវគ្គបណ្តុះបណ្តាលច្រើន ដូចនៅកម្ពុជាយើងទេ ដោយគេចេញសេចក្តីសម្រេចបន្ថែមថ្មីមួយ ហើយនៅថ្នាក់ក្រោមរៀបចំការបណ្តុះបណ្តាលដោយខ្លួនឯងតែម្តង។ នៅប្រទេសបារាំងមានការបោះឆ្នោតច្រើន ដូចជាបោះឆ្នោតជ្រើសរើសប្រធា-នាធិបតី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងសភាអឺរ៉ុប និងការបោះឆ្នោតថ្នាក់ក្រោមជាតិ ដូចជាថ្នាក់តំបន់ ថ្នាក់ខេត្ត ក្រុង ហូតដល់ឃុំ សង្កាត់។

ឯកឧត្តម **ទេព នីថា** បានមានប្រសាសន៍ទៀតថា នៅថ្ងៃចុងក្រោយ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន និងប្រតិភូ បានជួបលោកស្រី Mathilde TERUYA នាយិការង នៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ នៃក្រសួងការបរទេសបារាំង ដែលពេលនោះលោកស្រីបានលើកសរសើរអំពីស្ថានភាពល្អនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា និងថាបារាំងចង់ឃើញការរៀបចំការបោះឆ្នោតរបស់កម្ពុជា ស្របតាមគោលការណ៍ច្បាប់ និងដំណើរ-ការដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងពហុនិយម។ លោកស្រីក៏បានបន្ថែមថា តើកម្ពុជាចង់ឱ្យបារាំងជួយអ្វីខ្លះក្នុងការរៀបចំការបោះឆ្នោតខាងមុខនេះ។ ក្នុងប្រសាសន៍ឆ្លើយតបវិញ ឯកឧត្តមប្រធាន បានថ្លែងអំណរគុណចំពោះលោកស្រី និងបានជម្រាបអំពីដំណើរការល្អនៃការបោះឆ្នោតឃុំ សង្កាត់កាលពីឆ្នាំ២០២២ ដែលគណបក្សចំនួន ១៧ ឈរឈ្មោះ និងមានគណបក្ស ៩ ជាប់ឆ្នោតបានទទួលអាសនៈ។ ឯកឧត្តមប្រធានក៏បានជម្រាបជូនពីការត្រៀមរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅកម្ពុជា ដែលមានលក្ខណៈល្អប្រសើរ។បន្ថែមពីលើនេះឯកឧត្តមប្រធានគ.ជ.បក៏បានអញ្ជើញភាគីបារាំងមកសង្កេតការណ៍ការបោះឆ្នោតនៅកម្ពុជានាខែកក្កដាឆ្នាំ២០២៣ ខាងមុខ។

សរុបមកវិញឯកឧត្តម**ទេព នីថា**បានវាយតម្លៃជារួមថា ដំណើរទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋបារាំង បានដំណើរការបានល្អប្រសើរ និងជោគជ័យផងដែរ។

សូមរំឭកថា ដំណើរទស្សនកិច្ចនេះបានធ្វើឡើង បន្ទាប់ពីជំនួបរវាងសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជាកាលពីថ្ងៃទី១ ខែវិច្ឆិកា



**សកម្មភាពសន្និសីទសារព័ត៌មាន**

ឆ្នាំ២០២២ ដែលភាគីបារាំងបានលើកឡើងពីគោលបំណងផ្តល់ការគាំទ្រដល់កិច្ចការពាក់ព័ន្ធនឹងការងារបោះឆ្នោតនៅកម្ពុជា តាមរយៈការរៀបចំដំណើរទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការងារ នៅសាធារណរដ្ឋបារាំង។ សមាសភាពនៃគណៈប្រតិភូកម្ពុជា រួមមានថ្នាក់ដឹកនាំ គ.ជ.ប និងមន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃកម្ពុជា៕

## គ.ជ.ប ចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រកាសចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីចូលរួមសង្កេតការណ៍ក្នុងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ-២០២៣ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។ យោងតាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ កាលបរិច្ឆេទនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវបញ្ចប់ត្រឹមថ្ងៃទី១២ ខែកក្កដា និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ សម្រាប់អ្នកសង្កេតការណ៍អន្តរជាតិ។

សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិទាំងអស់ ដែលមានបំណងចូលរួមសង្កេតមើលការបោះឆ្នោតនេះ ត្រូវមកដាក់ពាក្យនៅទីស្តីការ គ.ជ.ប (ការិយាល័យកិច្ចការគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាន់ទី៩)។ គំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមានផ្តល់ជូនដោយឥតគិតថ្លៃនៅទីស្តីការ គ.ជ.ប ឬ អាចទាញយកពីគេហទំព័រ គ.ជ.ប (www.nec.gov.kh/khmer/content/6536)។

អ្នកសង្កេតការណ៍ជាតិ ដែលត្រូវបានអនុញ្ញាតជាផ្លូវការពី គ.ជ.ប និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិពីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) មានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតនៅរាជធានី ខេត្តដែលខ្លួនមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ជាតិនៃរាជធានីខេត្តនោះតែប៉ុណ្ណោះ។ ដោយឡែក អ្នកសង្កេតការណ៍អន្តរជាតិ ដែលត្រូវបានអនុញ្ញាតជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ ពី គ.ជ.ប មានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទី-កន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

គ.ជ.ប សង្ឃឹមទុកជាមុនថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន នឹងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដើម្បីជំរុញឱ្យការបោះឆ្នោតនេះប្រព្រឹត្តទៅដោយជោគជ័យ ដោយអនុលោមតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជាធរមាន និងឈរលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស៕

## គ.ជ.ប ចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រកាសចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដើម្បីចូលរួមយកព័ត៌មានក្នុងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧

ឆ្នាំ២០២៣ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។ យោងតាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ កាលបរិច្ឆេទនៃការចុះឈ្មោះអ្នកសារព័ត៌មានជាតិ ត្រូវបញ្ចប់ត្រឹមថ្ងៃទី១២ ខែកក្កដា និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ។

គ.ជ.ប មានផ្តល់ជូនដោយឥតគិតថ្លៃនូវគំរូពាក្យសុំ និងបែបបទសម្រាប់សុំបណ្ណសម្គាល់អ្នកសារព័ត៌មាន នៅទីស្តីការ គ.ជ.ប (ជាន់ទី៨ បន្ទប់ B) ឬអាចទាញយកពីគេហទំព័រ គ.ជ.ប www.nec.gov.kh/khmer/content/6427។ នៅពេលបំពេញបែបបទតាមទម្រង់រួចរាល់ អ្នកសារព័ត៌មានអាចយកពាក្យមកដាក់ដោយផ្ទាល់នៅ គ.ជ.ប ឬអាចផ្ញើតាមរយៈអ៊ីម៉ែល: info@nec.gov.kh ឬតេឡេក្រាម (០៩៣ ៨០២ ៧៣៤)។

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលទទួលបានការអនុញ្ញាតជាផ្លូវការ និងមានបណ្ណសម្គាល់អ្នកសារព័ត៌មាន សម្រាប់យកព័ត៌មានក្នុងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ត្រូវគោរពច្បាប់ បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត សេចក្តីណែនាំផ្សេងៗ ព្រមទាំងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។

សូមជម្រាបជូនថា នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធ គ.ជ.ប បានប្រកាសបើកដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងបានអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ចូលរួមសហការជាមួយ គ.ជ.ប ដើម្បីធ្វើយ៉ាងណាធានាឱ្យដំណើរការនេះប្រព្រឹត្តទៅដោយរលូន និងជោគជ័យ៕

# ឯកឧត្តមប្រធាន គ.ជ.ប ជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃ គ.ជ.ប ក្នុងថ្ងៃទិវាអន្តរជាតិនារី

នាឱកាសខួបអនុស្សាវរីយ៍លើកទី១១២ ទិវាអន្តរជាតិនារី នៅព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃ គ.ជ.ប ក្រោមប្រធានបទ **"ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល"**។

មានមតិសំណេះសំណាលក្នុងពិធីនោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានលើកឡើងថា ទិវាអន្តរជាតិនារី ៨មីនា ជាថ្ងៃដែលសកលលោករំលឹកអំពីវីរភាពនៃការតស៊ូរបស់នារីទូទាំងសកលលោក ដើម្បីទាមទារឱ្យមានការលើកកម្ពស់ស្ថានភាពជីវភាព សិទ្ធិសេរីភាព ឋានៈតួនាទីស្ត្រី នៅក្នុងសង្គម។ ឯកឧត្តមសូមគាំទ្រដល់ប្រធាន-បទ **"ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល"** ដែលបានលើកឡើងចំពេលដែល គ.ជ.ប បាននិងកំពុងរៀបចំដំណើរការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូននៃខេត្តកណ្តាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យនៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យនៃខេត្តក្រចេះ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ឯកឧត្តមបានបន្តថា បច្ចុប្បន្នមន្ត្រីបុគ្គលិកនៃ គ.ជ.ប ទាំងក្របខណ្ឌ និងជាប់កិច្ចសន្យារយៈពេលវែងមានចំនួន ៧៥១នាក់ ដែលក្នុងនោះមាននារីចំនួន ១៨០នាក់។ ឯកឧត្តមបានកត់សម្គាល់ឃើញថា ក្នុងចំណោមមន្ត្រីជានារី ១៨០នាក់ មាននារី ១៥០នាក់ ដែលមានកម្រិតវប្បធម៌ថ្នាក់ឧត្តមសិក្សា។ នេះជាសញ្ញាណវិជ្ជមានឆ្លុះបញ្ចាំងឱ្យឃើញពីភាពរីកចម្រើន និងឱកាសកាន់តែទូលាយរបស់ស្ត្រីក្នុងការទទួលបានការអប់រំកម្រិតខ្ពស់ និងបង្ហាញថា ស្ត្រីពិតជាមានចំណេះដឹង សមត្ថភាព និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកាន់មុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់ គ.ជ.ប ព្រមទាំងរួមចំណែកក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបោះ-



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

ឆ្នោតថែមទៀត។

ឯកឧត្តមប្រធាន គ.ជ.ប បានបញ្ជាក់បន្ថែមទៀតថា បច្ចុប្បន្ន ក្នុងស្ថាប័ន គ.ជ.ប ស្ត្រីកាន់មុខតំណែងជាអ្នកគ្រប់គ្រងមានថ្នាក់អគ្គនាយករង ជាជំនួយការ គ.ជ.ប ឋានៈស្មើប្រធាននាយកដ្ឋាន ជាអនុប្រធាននាយកដ្ឋាន ជាប្រធាន និងសមាជិកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ជាប្រធានលេខាធិការដ្ឋានខេត្តរៀបចំការបោះឆ្នោត ជាប្រធានការិយាល័យ ជាអនុប្រធានការិយាល័យ និងជាប្រធានផ្នែកជំនាញនៃលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែលនេះបញ្ជាក់ឱ្យឃើញពីការគិតគូរ យកចិត្តទុកដាក់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំ គ.ជ.ប ក្នុងការលើកកម្ពស់តម្លៃស្ត្រី និងផ្តល់ឱកាសដល់ស្ត្រីបានចូលរួមចំណែកក្នុងការថែរក្សាសន្តិភាព និងអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការរៀបចំការបោះឆ្នោត ដែលប្រកបដោយភាពសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានទំនើបកម្ម ស្របតាមប្រធានបទ និងចក្ខុវិស័យរបស់ គ.ជ.ប។

លើសពីនេះទៀត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានសង្កេតឃើញថា ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន មាននារីច្រើនជាងបុរស ដែលបានចូលប្រឡូកក្នុងសកម្មភាពការងារលើគ្រប់វិស័យ ដាក់ស្តែងនៅ



**មន្ត្រីរាជការ គ.ជ.ប ចូលរួមក្នុងពិធីសំណេះសំណាល**

ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ក៏មានចំនួននារីច្រើនជាងបុរសដែរ។ ឯកឧត្តមបានបន្តថា នារីតែងច្រើនជាងបុរស ដូចជាផ្នែកកម្មករ កម្មការនី វិស័យគ្រូបង្រៀន វិស័យគ្រូពេទ្យ វិស័យកសិកម្ម វិស័យកីឡាក៏មាននារីច្រើន។ល។

ឆ្លៀតក្នុងឱកាសពិធីខួបអបអរសាទរទិវាអន្តរជាតិនារីដ៏វិសេសវិសាល ឯកឧត្តមប្រធាន បានមានមតិផ្តាំផ្ញើដល់មន្ត្រីបុគ្គលិកនារីនៃ គ.ជ.ប ទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរ និងកិត្តិយសឱ្យបានល្អ និងមានសីលធម៌រស់នៅស្អាតស្អំ មានចរិយាសុភាពរាបសារ តែម៉ឺងម៉ាត់ ដើម្បីធ្វើជាគំរូល្អដល់នារីជំនាន់ក្រោយ។ នារីគ្រប់រូបត្រូវខិតខំបង្កើនសមត្ថភាពជំនាញ ដើម្បី



**ឯកឧត្តម ប្រាជ្ញ ចន្ទ ជូនបាច់ផ្កាដល់តំណាងស្ត្រីមន្ត្រី គ.ជ.ប**

កសាងខ្លួនទៅអនាគត តាមរយៈការអានសៀវភៅ ការស្រាវជ្រាវ ការបន្តការសិក្សា និងការតាមដានព័ត៌មានត្រឹមត្រូវ។ ត្រូវចេះប្រើប្រាស់ពេលវេលាឱ្យបានល្អ និងមិនត្រូវបណ្តែតបណ្តោយឱ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍។ នារីត្រូវចេះបែងចែកការទទួលខុសត្រូវការងារនៅអង្គភាព និងកិច្ចការគ្រួសារផ្ទាល់ ព្រមទាំងការសិក្សាបង្កើនសមត្ថភាព ដើម្បីជានាដោគជ័យក្នុងការងារផង និងសុភមង្គលក្នុងគ្រួសារផង។

ជាចុងក្រោយ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបន្ថែមទៀតថា ក្នុងតួនាទីជាម្តាយ ជាជីដូន និងឧត្តមភរិយា ស្ត្រីត្រូវអប់រំកូនចៅឱ្យខិតខំរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ និងត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន និងល្បែងស៊ីសងគ្រប់ប្រភេទ។ ពេលនិយាយស្តីត្រូវប្រកាន់យកភាពទន់ភ្លន់ សុភាពរាបសារ និងសីលធម៌ មិនប្រើអំពើហិង្សា មិនរំលោភសិទ្ធិអ្នកដទៃ ចៀសវាងពាក្យអសុរោះ ដើម្បីឱ្យពួកគេក្លាយជាកុលបុត្រ កុលធីតាល្អប្រសើររបស់សង្គមជាតិ ចេះគោរពច្បាប់ និងចេះអត់ឱន អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក៕

# គ.ជ.ប កម្ពុជា និង គ.ជ.ប ប៉ាឡេស្ទីន បានជួបផ្លាស់ប្តូរទស្សនៈ និងបទពិសោធន៍ ពាក់ព័ន្ធនឹងការងាររៀបចំការបោះឆ្នោត

តបតាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៃរដ្ឋប៉ាឡេស្ទីន និងដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប នៅព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នៅទីស្តីការ គ.ជ.ប ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប ដឹកនាំមន្ត្រីជាន់ខ្ពស់ គ.ជ.ប ទទួលជួបប្រតិភូ គ.ជ.ប ប៉ាឡេស្ទីន ដឹកនាំដោយលោក **អាស្រាហ្វ ស៊ូអាប៊ី** (Ashraf SHUAIBI) អគ្គលេខាធិការរង គ.ជ.ប ប៉ាឡេស្ទីន ក្រោមកិច្ចសម្របសម្រួលពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំកម្ពុជា ដើម្បីសម្តែងការគួរសម និងផ្លាស់ប្តូរទស្សនៈ និងបទពិសោធន៍ពាក់ព័ន្ធនឹងការងាររៀបចំការបោះឆ្នោត។

បន្ទាប់ពីភាគីទាំងពីរបានមានមតិស្វាគមន៍ចំពោះគ្នារួចមក ឯកឧត្តម **ទេព នីថា** បានជម្រាបជូនប្រតិភូប៉ាឡេស្ទីនអំពីប្រវត្តិនៃការបោះឆ្នោតនៅប្រទេសកម្ពុជា។ ឯកឧត្តមបានមានប្រសាសន៍ថា នៅឆ្នាំ១៩៩៣ កម្ពុជាមានការបោះឆ្នោតសកលធម្មនុញ្ញ ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ហើយចាប់តាំងពីឆ្នាំ១៩៩៨ កម្ពុជារៀបចំការបោះឆ្នោតដោយខ្លួនឯង ដោយមានការគាំទ្រពីអង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ ដូចជា សហភាពអឺរ៉ុប និងទីភ្នាក់ងារ JICA ជាដើម ក្នុងនោះរួមមាន ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការ



លោក អាស្រាហ្វ ស៊ូអាប៊ី អគ្គលេខាធិការរង គ.ជ.ប ប៉ាឡេស្ទីន

បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប បានគូសបញ្ជាក់ជូនថា ចាប់តាំងពីឆ្នាំ២០១៥ មក កម្ពុជាបានធ្វើកំណែទម្រង់ស៊ីជម្រៅលើការបោះឆ្នោតរបស់ខ្លួន ដោយបានដាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅក្នុងរដ្ឋធម្មនុញ្ញ។ សមាជិក គ.ជ.ប ត្រូវបានជ្រើសតាំងដោយរដ្ឋសភា។

ឯកឧត្តមបានបន្តថា គ.ជ.ប បានធ្វើកំណែទម្រង់លើការចុះឈ្មោះបោះឆ្នោត ដោយប្តូរពីការចុះឈ្មោះដោយដៃ មកជាការចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រ។ ឯកឧត្តមបានជម្រាបបន្ថែម



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

ថា ក្រៅពីនោះ គ.ជ.ប បានអភិវឌ្ឍការរៀបចំការបោះឆ្នោតឱ្យកាន់តែមានភាពងាយស្រួល និងមានទំនើបកម្ម តាមរយៈការដាក់ឱ្យប្រើប្រាស់៖

- កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ
- កម្មវិធីចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)
- កម្មវិធីស្វែងរកបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- កម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ បូកសរុបលទ្ធផលនៃការបោះឆ្នោត ការបែងចែកអាសនៈ និងការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត



សកម្មភាពក្នុងជំនួបពិភាក្សា

- កម្មវិធីគ្រប់គ្រងសំណុំរឿង និងរបាយការណ៍ពាក់ព័ន្ធនឹងពាក្យបណ្ដឹង។

ឯកឧត្តមអគ្គលេខាធិការ បានមានប្រសាសន៍ថា នៅក្នុងឆ្នាំ២០២៣ នេះ កម្ពុជាកំពុងរៀបចំការបោះឆ្នោតចំនួន ២ នោះគឺការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ដែលទើបបំបែក និងបង្កើតថ្មី។

បន្ទាប់ពីបានស្ដាប់ប្រសាសន៍របស់ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប កម្ពុជា យ៉ាងយកចិត្តទុកដាក់រួចមក ប្រតិភូ គ.ជ.ប ប៉ាឡេស្ទីន បានវាយតម្លៃខ្ពស់ចំពោះការចុះឈ្មោះបោះឆ្នោតនៅកម្ពុជា ដែលមានចំនួនដល់ទៅជាង ៨០ ភាគរយ។ ប្រតិភូ ប៉ាឡេស្ទីន ក៏បានសង្កេតឃើញ និងកោតសរសើរចំពោះវគ្គអប់រំអ្នកបោះឆ្នោតបន្ត ដែល គ.ជ.ប កម្ពុជា សហការជាមួយ JICA បាននិងកំពុងរៀបចំនៅតាមគ្រឹះស្ថានសិក្សានានា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតជូនដល់យុវជន។

ជាចុងបញ្ចប់ ភាគី គ.ជ.ប កម្ពុជា និង គ.ជ.ប ប៉ាឡេស្ទីន មានការជឿជាក់ថា គ.ជ.ប ទាំងពីរនឹងមានកិច្ចសហការ ការចែករំលែក ការផ្លាស់ប្ដូរបទពិសោធន៍ និងការអនុវត្តល្អៗជាបន្តបន្ទាប់ទៀត តាមរយៈកិច្ចសម្របសម្រួលពីទីភ្នាក់ងារ JICA។

ជំនួបពិភាក្សាបានប្រព្រឹត្តទៅរយៈពេលមួយម៉ោង ក្នុងបរិយាកាសរីករាយ ស្និទ្ធស្នាល និងយោគយល់គ្នា៕

# គ.ជ.ប បើកវគ្គបណ្ដុះបណ្ដាលស្ដីពី របៀបប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នៅព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី របៀបប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ជូនដល់តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ តំណាងក្រសួងមហាផ្ទៃ តំណាងគណបក្សនយោបាយ និងមន្ត្រីបុគ្គលិក គ.ជ.ប សរុបប្រមាណ ១០៨ នាក់ នៅទីស្ដីការ គ.ជ.ប។

កន្លងមកនេះ ក្នុងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គ.ជ.ប បានដាក់ឱ្យប្រើប្រាស់កម្មវិធីរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយម្ដងរួចហើយ ហើយកិច្ចការនេះទទួលបានលទ្ធផលជោគជ័យ គឺកាត់បន្ថយបាននូវបញ្ហាប្រឈមនានា។

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ គ.ជ.ប បានសម្រេចដាក់ឱ្យប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដើម្បីចៀសវាងនូវបញ្ហាប្រឈមមួយចំនួន ដូចជា៖

- បេក្ខជនខុសឈ្មោះ និងទិន្នន័យ



**ឯកឧត្តម ម៉ុក ដារ៉ា អគ្គលេខាធិការរង គ.ជ.ប**

- បេក្ខជនមិនគ្រប់អាយុសម្រាប់ការឈរឈ្មោះបោះឆ្នោត
- បេក្ខជនឈរឈ្មោះច្រើនជាងមួយគណបក្សនយោបាយ
- បេក្ខជនឈរឈ្មោះច្រើនមណ្ឌល។

វគ្គបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅអស់រយៈពេលពេញ ១ ព្រឹក ដោយមានការធ្វើបទបង្ហាញពីមន្ត្រីជំនាញ គ.ជ.ប ការអនុវត្តកម្មវិធីដាក់ស្តែងដោយសិក្ខាកាម និងការចោទជាសំណួរ និងការបកស្រាយយ៉ាងផុលផុស។

វគ្គបណ្តុះបណ្តាលនេះត្រូវបានបិទបញ្ចប់ក្រោមអធិបតីភាពឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប។ នាឱកាសនោះ ឯកឧត្តមបានមានប្រសាសន៍ថា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ គ.ជ.ប បានចេញសេចក្តីជូនដំណឹងស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ តាមរយៈសេចក្តីជូនដំណឹងនេះ គ.ជ.ប បានកំណត់កាលបរិច្ឆេទក្នុងការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មានរយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី២៤ ខែមេសា ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងវគ្គបណ្តុះបណ្តាល**

ឯកឧត្តមបានថ្លែងថា ការរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មាន ២ របៀបគឺ៖

១- គណបក្សនយោបាយអាចរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដោយដៃ។



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងវគ្គបណ្តុះបណ្តាល**

២- គណបក្សនយោបាយអាចស្នើសុំបង្កើតគណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមកម្មវិធី (ប្រព័ន្ធកុំព្យូទ័រ)។

ឯកឧត្តមបានគូសបញ្ជាក់ថា ការទទួលពាក្យសុំបង្កើតគណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គឺចាប់ពីថ្ងៃទី១ ខែមីនា ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។

ឯកឧត្តម **ម៉ុក ដារ៉ា** បានមានប្រសាសន៍ថា គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា គ្រប់គណបក្សនយោបាយ និងភាគីពាក់ព័ន្ធទាំងអស់នឹងបន្តសហការល្អក្នុងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ៕

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃចន្ទ ៩រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសារព័ត៌មានជាតិនៅ គ.ជ.ប | ថ្ងៃទី១ ខែមេសា-១២ ខែកក្កដា ឆ្នាំ២០២៣ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិនៅ គ.ជ.ប | ថ្ងៃទី១ ខែមេសា-១៩ខែកក្កដា ឆ្នាំ២០២៣ |
| ៣ | ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជននៅ គ.ជ.ប រយៈពេល ១៥ថ្ងៃ | ថ្ងៃទី២៤ ខែមេសា-៨ ខែឧសភា ឆ្នាំ២០២៣ |
| ៤ | ការប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះបញ្ជីគណបក្សទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២៦ខែឧសភា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៥ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី៥ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៦ | ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត | ថ្ងៃទី២៨ខែឧសភា-២៦ ខែមិថុនា ឆ្នាំ២០២៣ |
| ៧ | ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមមណ្ឌលរាជធានី ខេត្ត | ថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៨ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ក្នុងរយៈពេល ៧ថ្ងៃ ក្រោយថ្ងៃបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមមណ្ឌលរាជធានី ខេត្ត | ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ៩ | ការបិទផ្សាយបញ្ជីឈ្មោះ ទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតនៅ គឃ.សប | ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ |
| ១០ | ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរយៈពេល៣០ថ្ងៃ | ថ្ងៃទី២២ខែមិថុនា-២១ ខែកក្កដា ឆ្នាំ២០២៣ |
| ១១ | ការឃោសនាបោះឆ្នោត | ថ្ងៃទី១ ខែកក្កដា - ២១ ខែកក្កដា ឆ្នាំ២០២៣ |
| ១២ | ការបិទផ្សាយបញ្ជីបោះឆ្នោត និងលេខកូដការិយាល័យបោះឆ្នោត នៅការិយាល័យបោះឆ្នោត | ថ្ងៃទី២២ខែកក្កដា ឆ្នាំ២០២៣ |
| ១៣ | ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី២៣ខែកក្កដា ឆ្នាំ២០២៣ |
| ១៤ | ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត | ថ្ងៃទី២៣-២៤ ខែកក្កដា ឆ្នាំ២០២៣ |
| ១៥ | ការប្តឹងតវ៉ាទៅ គឃ.សប អំពីលទ្ធផលនៃការបោះឆ្នោត ឬភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោត | ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ (យ៉ាងយូរត្រឹមម៉ោង ១១:៣០នាទី) |
| ១៦ | គឃ.សប សម្រេចលើពាក្យបណ្តឹងត្រួតពិនិត្យបូកសរុបលទ្ធផល ធ្វើកំណត់ហេតុ និងបិទផ្សាយកំណត់ហេតុ | ថ្ងៃទី២៤-២៥ ខែកក្កដា ឆ្នាំ២០២៣ |
| ១៧ | ការប្តឹងតវ៉ាទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គឃ.សប | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ១៨ | ការដោះស្រាយពាក្យបណ្តឹងដោយ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង | ថ្ងៃទី៣០ខែកក្កដា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ១៩ | ការប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គធ.ខប | ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២០ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង | ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២១ | ការប្រកាសលទ្ធផលបណ្តោះអាសន្នដោយ គ.ជ.ប (ករណីគ្មានការបោះឆ្នោតសាជាថ្មី) | ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ |
| ២២ | ការប្តឹងតវ៉ាទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីលទ្ធផលបណ្តោះអាសន្ន ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង | ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៣ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៤ | ការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីទទួលលិខិតបដិសេធរបស់ គ.ជ.ប | ថ្ងៃទី១៤ខែសីហា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៥ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរពី ១០-២០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៦ | ការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន) | ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ) |
| ២៧ | ប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោត (តាមករណីគ្មាន ឬមានបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី) | ថ្ងៃទី៩ ខែសីហា-ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ |


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh



រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News